# រដ្ឋវ៉ាស៊ីនតោន
# តម្រូវការថង់

## សម្រាប់ភោជនីយដ្ឋាន និងអាជីវកម្មសេវាកម្មអាហារផ្សេងទៀត



**ហាម**

**ប្រើប្រាស់ថង់យួរប្លាស្ទិកដែលអាចប្រើបានតែមួយដង**



**តម្លៃ 8¢**

**ថង់យួរក្រដាសធំ**

ធ្វើពីសារធាតុអាចប្រើប្រាស់ឡើងវិញ 40% តម្លៃត្រូវបានរក្សានៅសភាពដើមដោយអាជីវកម្ម។




**តម្លៃ 8¢**

**ថង់យួរប្លាស្ទិកក្រាស់ដែលអាចប្រើបាស់ឡើងវិញ**

ធ្វើពីសារធាតុអាចប្រើប្រាស់ឡើងវិញ 20% និងមានហ្វីមក្រាស់អប្បបរមា 2.25 មម។ តម្លៃត្រូវបានរក្សានៅសភាពដើមដោយអាជីវកម្ម។

## ថង់ផ្សេងៗទៀត ដែលត្រូវបានអនុញ្ញាត៖



ថង់ចកែដលអាចប្រើបាស់ឡើងវិញស្អាត



ថង់ក្រដាសតូច




ថង់តូចស្រមាប់ការគ្រប់គងសំណើម

DEPARTMENT OF ECOLOGY
State of Washington

**(360) 407-6000 | bagban@ecy.wa.gov | Ecology.wa.gov/Bag-Ban**

ដើម្បីស្នើសុំការសម្រុះសម្រួល ADA សូមទាក់ទងផ្នែកបរិស្ថានវិទ្យាតាមរយៈទូរសព្ទលេខ 360-742-9874 ឬអ៊ីម៉ែលតាមរយៈ bagban@ecy.wa.gov ឬចូលទៅកាន់ https://ecology.wa.gov/accessibility ។ សម្រាប់សេវាកម្ម Relay Service ឬ TTY សូមទូរសព្ទទៅលេខ 711 ឬ 877-833-6341។ ប្រសិនបើអ្នកមិននិយាយភាសាអង់គ្លេស សេវាបម្រើភាសាឥតគិតថ្លៃមានសម្រាប់លោកអ្នក។ ហៅទៅលេខ 360-742-9874។

# ព័ត៌មានលម្អិតអំពីច្បាប់ប្រើប្រាស់ថង់នៅរដ្ឋវ៉ាស៊ីនតោន

## កំណត់ចំណាំអាជីវកម្មសេវាកម្មអាហារ និងភោជនីយដ្ឋាន៖

- ភោជនីយដ្ឋានមិនគួរផ្តល់ឱ្យអតិថិជននូវថង់យួរប្លាស្ទិកសម្រាប់ការប្រើប្រាស់បានតែមួយដងនោះទេ
- ការហាមឃាត់ប្រើប្រាស់ថង់អនុវត្តចំពោះភោជនីយដ្ឋានទាំងអស់ ហាងលក់អាហារតូចៗ តូបលក់រាយ អ្នកលក់អាហារចំអិន ផ្សារគ្រឿងសារ ឡានលក់អាហារ អ្នកលក់អាហារសម្រាប់កម្មវិធីផ្សេងៗ តូបលក់អាហារ ភោជនីយដ្ឋានបណ្តោះអាសន្ន អាហារដឹកជញ្ជូននិងអាហារវេចខ្ចប់។ ឃ្លាំងអាហារត្រូវបានលើកលែង។
- ប្រសិនបើអ្នកមានសំណួរអំពីរបៀបដែលអាជីវកម្មរបស់អ្នកត្រូវអនុលោមទៅតាមការហាមឃាត់នេះ សូមទាក់ទងទៅ **bagban@ecy.wa.gov** ។
- ភោជនីយដ្ឋានត្រូវតែគិតតម្លៃអប្បបរមាក្នុងតម្លៃ 8 សេនសម្រាប់ថង់ក្រដាសធំ។ (ថង់ក្រដាសបារ៉ែល 1/8 882 អ៊ីញគូប ឬធំជាងនេះ) និងថង់ប្លាស្ទិកដែលអាចប្រើប្រាស់បានឡើងវិញ (2.25 មម ឬក្រាស់ជាងនេះ)។
- ថង់ក្រដាសធំដែលអតិថិជនត្រូវទិញ ត្រូវតែមានសារធាតុដែលអាចប្រើប្រាស់ឡើងវិញបន្ទាប់ពីប្រើប្រាស់យ៉ាងហោចណាស់ 40% ដែលបោះពុម្ពនៅលើផ្នែកខាងក្រៅនៃថង់។
- ថង់ហ្វីមប្លាស្ទិកដែលអតិថិជនត្រូវទិញ ត្រូវតែមានសារធាតុដែលអាចកែច្នៃឡើងវិញបានបន្ទាប់ពីប្រើប្រាស់យ៉ាងហោចណាស់ 20% ដែលមានកម្រាស់ជា មម និងមានពាក្យ «អាចប្រើប្រាស់ឡើងវិញ (Reusable)» បោះពុម្ពនៅផ្នែកខាងក្រៅនៃថង់។
- ភោជនីយដ្ឋានអាចផ្តល់ជូននូវថង់ក្រដាសដែលតូចជាងនេះ។ ការគិតតម្លៃគឺជាជម្រើស។
- ភោជនីយដ្ឋានអាចប្រើប្រាស់ថង់ហ្វីមតូចដើម្បីដាក់កំប៉ុងដាក់សារធាតុរាវមុននឹងដាក់ទៅក្នុងថង់យួរដែលបានអនុញ្ញាត។
- ការគិតថ្លៃថង់គឺជាការលក់រាយដែលអាចគិតពន្ធ ហើយត្រូវតែបង្ហាញលើវិក្កយបត្ររបស់អតិថិជន។ ភោជនីយដ្ឋានត្រូវតែរក្សាប្រាក់ចំណូលថ្លៃថង់របស់ខ្លួនទាំង។
- ភោជនីយដ្ឋានអាចផ្តល់ជូនថង់ហ្វីមដែលអាចពុកផុយជាជីដោយមានការបញ្ជាក់សម្រាប់ការគិតតម្លៃទៅតាមជម្រើស។ ការធ្វើបែបនេះមិនត្រូវបានណែនាំសម្រាប់តំបន់ភាគច្រើននៅក្នុងរដ្ឋវ៉ាស៊ីនតោននោះទេ។
- រាល់ថង់ដែលមានពណ៌បៃតង ឬត្នោតនៅលើថង់ត្រូវតែអាចពុកផុយជាជីបាន។
- ភោជនីយដ្ឋានមិនគួរផ្តល់ថង់ដល់អតិថិជនដែលមានរូបសញ្ញានាំឱ្យមានការភាន់ច្រឡំដូចជា «អាចបំបែកសរីរាង្គបាន (biodegradable)» «អាចបំបែកបាន (degradable)» «អាចធ្វើជាជីបាន (decomposable)» ឬដែលស្រដៀងគ្នានោះទេ។
- មនុស្សគ្រប់គ្នាអាចរាយការណ៍ពីអាជីវកម្មដែលមិនបានអនុលោមតាមបម្រាមដោយប្រើប្រាស់ទម្រង់បែបបទអនឡាញដែលផ្តល់ជូនដោយនាយកដ្ឋានផ្នែកបរិស្ថានវិទ្យា។
- អាជីវកម្មអាចមិនគិតថ្លៃថង់ចំពោះអតិថិជនដែលប្រើប្រាស់/បង្ហាញនូវបណ្ណបញ្ចុះតម្លៃ ឬបណ្ណអត្ថប្រយោជន៍ (SNAP, WIC, TANF, FAP)។

## ជួយអតិថិជនរបស់អ្នកការពារបរិស្ថាននិងកាត់បន្ថយសំរាមប្លាស្ទិក។




សូមចូលទៅគេហទំព័រ បរិស្ថានវិទ្យា WA ដើម្បីមើល កែតម្រូវតាមការចង់បាន និងបោះពុម្ពឯកសារ BYOB (ប្រើប្រាស់ថង់ផ្ទាល់ខ្លួន, Bring Your Own Bag) ដែលផ្តល់ការអប់រំនៅថ្ងៃនេះ។

**ecology.wa.gov/bag-ban**

## មានសំណួរមែនទេ?

bagban@ecy.wa.gov or (360) 407-6000



ដើម្បីស្នើសុំការសម្រុះសម្រួល ADA សូមទាក់ទងផ្នែកបរិស្ថានវិទ្យាតាមរយៈទូរសព្ទលេខ 360-742-9874 ឬអ៊ីម៉ែលតាមរយៈ bagban@ecy.wa.gov ឬចូលទៅកាន់ https://ecology.wa.gov/accessibility ។ សម្រាប់សេវាកម្ម Relay Service ឬ TTY សូមទូរសព្ទទៅលេខ 711 ឬ 877-833-6341។
ប្រសិនបើអ្នកមិននិយាយភាសាអង់គ្លេស សេវាបម្រើភាសាឥតគិតថ្លៃមានសម្រាប់លោកអ្នក។ ហៅទៅលេខ 360-742-9874។

# រដ្ឋវ៉ាស៊ីនតោន
# តម្រូវការថង់
## សម្រាប់ភោជនីយដ្ឋាន និងអាជីវកម្មសេវាកម្មអាហារផ្សេងទៀត











### ហាម
**ប្រើប្រាស់ថង់យួរប្លាស្ទិកដែលអាចប្រើបានតែមួយដង**

### តម្លៃ 8¢
**ថង់យួរក្រដាសធំ**

ធ្វើពីសារធាតុអាចប្រើប្រាស់ឡើងវិញ 40% ការគិតតម្លៃត្រូវតែរក្សានៅសភាពដើមដោយអាជីវកម្ម

### តម្លៃ 8¢
**ថង់យួរប្លាស្ទិកក្រាស់ដែលអាចប្រើប្រាស់ឡើងវិញ**

ធ្វើពីសារធាតុអាចប្រើប្រាស់ឡើងវិញ 20% និងមានហ្វីមក្រាស់អប្បបរមា 2.25 មម។ ការគិតតម្លៃត្រូវតែរក្សានៅសភាពដើមដោយអាជីវកម្ម

### ការគិតតម្លៃផ្តល់ជាជម្រើស
**ថង់យួរ ដែលពុកផុយក្លាយជាជីត្រូវបានអនុញ្ញាតប៉ុន្តែមិនត្រូវបានណែនាំឱ្យប្រើប្រាស់**

ថង់ហ្វីមដែលមានដាក់ពណ៌ត្នោត ឬបៃតងត្រូវតែ ជាថង់អាចពុកផុយជាជីបាន។

## ថង់ផ្សេងៗទៀត ដែលត្រូវបានអនុញ្ញាត៖



ថង់ច្រកដែលអាចប្រើប្រាស់ឡើងវិញស្អាត



ថង់ក្រដាសតូច




ថង់តូចសម្រាប់ការគ្រប់គងសំណើម

DEPARTMENT OF ECOLOGY
State of Washington

(360) 407-6000 | bagban@ecy.wa.gov | Ecology.wa.gov/Bag-Ban

ដើម្បីស្នើសុំការសម្រុះសម្រួល ADA សូមទាក់ទងផ្នែកបរិស្ថានវិទ្យាតាមរយៈទូរសព្ទលេខ 360-742-9874 ឬអ៊ីម៉ែលតាមរយៈ bagban@ecy.wa.gov ឬចូលទៅកាន់ https://ecology.wa.gov/accessibility ។ សម្រាប់សេវាកម្ម Relay Service ឬ TTY សូមទូរសព្ទទៅលេខ 711 ឬ 877-833-6341។ ប្រសិនបើអ្នកមិននិយាយភាសាអង់គ្លេស សេវាបម្រើភាសាឥតគិតថ្លៃមានសម្រាប់លោកអ្នក។ ហៅទៅលេខ 360-742-9874។